E350/7

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 06 / 2015
ម៉ោង (Time/Heure) : 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥

**ជូនចំពោះ÷** លោក Michael G. KARNAVAS
លោក អាង ឧត្តម
លោក សូ មូស្សេរ៉ា
លោកស្រី Suzana TOMANOVIĆ

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ភាគី ទាំងអស់ក្នុងសំណុំរឿង ០០២/០២

**កម្មវត្ថុ÷** សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់សារណា *របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ឬ ចូលរួមធ្វើអន្តរាគមន៍លើភាពអាចទទួលយកបាន និងការប្រើប្រាស់ភស្តុតាងដែលទទួលបានតាមរយៈទារុណកម្ម (ឯកសារ E350/5 និង E350/6)

១. អង្គជំនុំជម្រះបានទទួលសំណើពីក្រុមមេធាវីការពារក្តី មាស មុត ("ម្ចាស់សំណើសុំក្នុងសំណុំរឿង ០០៣") សុំអន្តរាគមន៍ក្នុងសំណុំរឿង ០០២/០២ ឬ ជម្រើសម្យ៉ាងទៀត សុំដាក់សារណា *របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ស្តីពីភាពអាចទទួលយកបាន និង ការប្រើប្រាស់ភស្តុតាងដែលទទួលបានតាមរយៈទារុណកម្មនៅក្នុងការជំនុំជម្រះចំពោះមុខ អ.វ.ត.ក (ឯកសារ E350/5)។ អង្គជំនុំជម្រះក៏បានទទួលសំណើមួយទៀតពីក្រុមមេធាវីការពារក្តីជនសង្ស័យមួយរូបផងដែរនៅក្នុងសំណុំរឿង ០០៤ ("ម្ចាស់សំណើសុំក្នុងសំណុំរឿង ០០៤") សុំ

ដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ស្ដីពីការប្រើប្រាស់នូវភស្តុតាងដែលទទួលបានតាមរយៈទារុណកម្ម (ឯកសារ 350/6) (ហៅរួមគ្នាថា“សំណើសុំ”)។

២. ក្រោយពីមានសំណើសុំមួយពីសហព្រះរាជអាជ្ញានៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ រួចមក អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគីនៅក្នុងសំណុំរឿង ០០២/០២ ដាក់សារណាជាលាយលក្ខណ៍អក្សរនៅត្រឹមថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ស្ដីពីភាពអាចទទួលយកបាន និង ការប្រើប្រាស់ដោយស្របច្បាប់នូវភស្តុតាងដែលអាចត្រូវបានទទួលតាមរយៈទារុណកម្ម (ឯកសារ E350/4.2)។ អង្គជំនុំជម្រះបានទទួលសារណាជាលាយលក្ខណ៍អក្សរពីគ្រប់ភាគីទាំងអស់ (ឯកសារ E350, E350/1, E350/3, E350/4) ហើយបានស្ដាប់ទឡ្ហីករណ៍ផ្ទាល់មាត់លើបញ្ហានេះកាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ (ឯកសារ E1/304.1)។

៣. ម្ចាស់សំណើសុំក្នុងសំណុំរឿង ០០៣ អះអាងថា ការអន្តរាគមន៍របស់ខ្លួនចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋានថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពអាចទទួលយកបាន និង ការប្រើប្រាស់ដោយស្របច្បាប់នូវភស្តុតាងដែលអាចត្រូវបានទទួលតាមរយៈទារុណកម្ម “នឹងបង្កើតជាយុត្តិសាស្ត្រមួយស្ដីពីភាពអាចទទួលយកបាន និង ការប្រើប្រាស់ភស្តុតាងទាំងនោះ ដែលជះឥទ្ធិពលលើការបង្ហាញភស្តុតាងរបស់លោក មាស មុត នៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងរឿងក្ដី ០០៣ ផង និង ដល់សហចៅក្រមស៊ើបអង្កេតផងដោយបង្កើតនូវការណែនាំស្ដីពីការប្រើប្រាស់សម្ភារៈបែបនេះ” (ឯកសារ E350/5 កថាខណ្ឌ ១៤)។ ម្ចាស់សំណើសុំរូបនេះក៏បានអះអាងទៀតថា ការអនុញ្ញាតឱ្យដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* លើបញ្ហានេះនឹងការពារសិទ្ធិ និង ផលប្រយោជន៍របស់ មាស មុត នៅក្នុងសំណុំរឿង ០០៣ (ឯកសារ E350/5 កថាខណ្ឌ ២៤)។ ម្ចាស់សំណើសុំក្នុងសំណុំរឿង ០០៤ សន្និដ្ឋានថា ដើម្បីឱ្យមានសច្ចភាពតាមផ្លូវច្បាប់នៅក្នុងការបកស្រាយច្បាប់ដោយ អ.វ.ត.ក និង ដើម្បីការវិនិច្ឆ័យឱ្យបានសមស្របលើសំណុំរឿង ០០២/០២ សំណុំរឿង ០០៣ និង សំណុំរឿង ០០៤ នោះ អង្គជំនុំជម្រះគួរអនុញ្ញាតឱ្យដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* លើបញ្ហាដែលបានស្នើឡើងនេះ (ឯកសារ E350/6 កថាខណ្ឌ ៧-៨)។

៤. វិធាន ៣៣ នៃវិធានផ្ទៃក្នុងចែងថា “នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ អង្គជំនុំជម្រះអាចអញ្ជើញ ឬ ផ្ដល់ឱកាសឱ្យអង្គការ ឬ បុគ្គលណាមួយ ដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សរពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បាន”។ អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលសំណើ

សុំដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* រួចមកហើយ ដោយអង្គជំនុំជម្រះទាំងនេះបានយល់ឃើញថា អង្គជំនុំជម្រះបានទទួលព័ត៌មានគ្រប់គ្រាន់លើបញ្ហាមួយនេះ ឬ ដោយសារថាការដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*នឹងធ្វើឱ្យមានការពន្យារពេលដោយពុំចាំបាច់ (*សូមមើល ខ.* ឯកសារ D99/3/17, D158/5/1/14, F16/3)។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចរួចហើយថា *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* "ពុំគួរមានការពាក់ព័ន្ធនឹងតុលាការ ឬ ការិយាល័យណាមួយរបស់តុលាការ" នោះទេ (ឯកសារ F20/1 កថាខណ្ឌ ៩)។ អង្គជំនុំជម្រះតុលាការកំពូលក៏បានសម្រេចរួចហើយផងដែរថា ខុសពីតួនាទីរបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* គ្មានបទប្បញ្ញត្តិជាក់លាក់ណាមួយនៅក្នុងច្បាប់ជាធរមាននៃ អ.វ.ត.ក ចែងពាក់ព័ន្ធនឹងភាគីអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធីនោះទេ (ឯកសារ F20/1 កថាខណ្ឌ ១០)។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ការពិចារណាជាសំខាន់នៅក្នុងការអនុញ្ញាតឱ្យធ្វើអន្តរាគមន៍គឺ "ថាតើជាផលប្រយោជន៍ស្របច្បាប់របស់ស្ថាប័នដែលស្នើសុំនោះ ហើយ បើត្រូវបានបដិសេធវិញនោះ ថាតើអាចរងផលប៉ះពាល់ដែរ ឬ យ៉ាងណា" (ឯកសារ F20/1 កថាខណ្ឌ ១១)។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា សំណើសុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងនាមជាភាគីអន្តរាគមន៍ "ត្រូវបានអនុញ្ញាត ប្រសិនបើកើតមាន ទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ" (ឯកសារ F20/1 កថាខណ្ឌ ១២)។

៥. អង្គជំនុំជម្រះយល់ស្របតាមសំអាងហេតុខាងលើនេះ។ ជាធម្មតា *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* គឺជាអ្នកប្រឹក្សាឯករាជ្យ និង អព្យាក្រឹត្យរបស់តុលាការដែលមានតួនាទីគ្រាន់តែជូនព័ត៌មាន ពុំមែនការពារក្តីនោះឡើយ (ឯកសារ E306/3/1 កថាខណ្ឌ ៥។ *សូមមើលផងដែរ* ឯកសារ D99/3/18.31)។ អង្គជំនុំជម្រះកត់សម្គាល់ថា ម្ចាស់សំណើសុំនៅក្នុងសំណុំរឿង ០០៣ បានគាំទ្រការអនុវត្តបទដ្ឋាននេះនៅក្នុងសេចក្តីសន្និដ្ឋានមុនៗនៅចំពោះមុខអង្គបុរេជំនុំ-ជម្រះនៅក្នុងសំណុំរឿង ០០១ (ឯកសារ D99/3/18 កថាខណ្ឌ ១១)។ អង្គជំនុំជម្រះយល់ឃើញថា ដោយហេតុថា ម្ចាស់សំណើសុំក្នុងសំណុំរឿង ០០៣ និង ០០៤ មានទំនាក់ទំនងជាមួយនឹងតុលាការ ឬ ការិយាល័យណាមួយរបស់តុលាការតាមរយៈតួនាទីជាមេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ពួកគេមិនអាចត្រូវបានចាត់ទុកថាជាអ្នកប្រឹក្សាឯករាជ្យ និង អព្យាក្រឹត្យរបស់តុលាការនោះទេ។ ម្យ៉ាងវិញទៀត ដោយពិចារណាលើគុណៈ និង វិសាលភាពនៃសេចក្តីសន្និដ្ឋានដែលភាគីបានទទួលនៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះ

សាលាដំបូងយល់ឃើញថា ការអនុញ្ញាតឱ្យដាក់សារណា*របស់អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងករណីនេះនឹងពុំមែនជាការចាំបាច់ក្នុងការសម្រេចឱ្យបានត្រឹមត្រូវលើបញ្ហាខាងលើនេះឡើយ។

៦. អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ផលប្រយោជន៍នៃយុត្តិធម៌ពុំតម្រូវឱ្យមានសំណើណាមួយពីម្ចាស់សំណើក្នុងសំណុំរឿង ០០៣ ដើម្បីសុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នក្នុងនាមជាភាគីអន្តរាគមន៍ឡើយ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ការស៊ើបអង្កេតកំពុងបន្តធ្វើឡើង ហើយសំណុំរឿង ០០៣ បច្ចុប្បន្ន កំពុងរង់ចាំការសម្រេចសេចក្តីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ហេតុដូច្នេះ ផលប្រយោជន៍ដែលម្ចាស់សំណើសុំក្នុងសំណុំរឿង ០០៣ បានលើកឡើង និង ផលប៉ះពាល់ដែលអាចបណ្តាលមកពីការច្រានចោលសំណើសុំអន្តរាគមន៍នេះ ពុំមានលក្ខណៈជាក់លាក់ និង គ្រាន់តែជាការស្មានៗតែប៉ុណ្ណោះនៅក្នុងដំណាក់កាលនេះ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជាការសមស្របដែលម្ចាស់សំណើសុំក្នុងសំណុំរឿង ០០៣ ត្រូវដាក់សំណើសុំនេះទៅអង្គភាពយុត្តាធិការពាក់ព័ន្ធនឹងសំណុំរឿង ០០៣ នេះ។

៧. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងច្រានចោលសំណើសុំទាំងពីរនេះ។